ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា

## របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីប្រកាសផ្សព្វផ្សាយក្រមច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨

សូមគោរព :

- លោក John Nelmes តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិនៅកម្ពុជា
- លោក Arjun Goswami ប្រធានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកជួបជាមួយ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាតំណាងមកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តំណាងប្រតិបត្តិករនិងបញ្ញត្តិករ និងតំណាងគ្រឹះស្ថានឧត្តមសិក្សា ក្នុងឱកាសដែលធនាគារជាតិនៃកម្ពុជា ប្រារព្ធពិធីប្រកាសផ្សព្វផ្សាយក្រមច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នាពេលនេះ ។ ពិធីនេះ ប្រារព្ធធ្វើឡើងដើម្បីផ្សព្វផ្សាយក្រមច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យកាន់តែស៊ីជម្រៅថែមទៀត លើផ្នែកវិសាលភាព និងខ្លឹមសារ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងនូវអំណរគុណ និងសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ មកកាន់អគារថ្មីរបស់ធនាគារជាតិនៃកម្ពុជា ដែលទើបសាងសង់រួច នាពេលថ្មីៗនេះ ។

ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី

ក្រោយពីការធ្វើកំណែទម្រង់សេដ្ឋកិច្ចរួចមក នៅដើមទសវត្សឆ្នាំ១៩៩០ ប្រទេសកម្ពុជា បានបើកចំហរទីផ្សារដើម្បីឱ្យមានការវិនិយោគបរទេស ។ ពេលនោះ សេដ្ឋកិច្ចចាប់ផ្តើមមានការរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យធនាគារចាប់ផ្តើមរីកចម្រើនយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់ផងដែរ ដោយមានធនាគារពាណិជ្ជខ្លះ បានបើកធ្វើប្រតិបត្តិការក្រោមរូបភាពនៃការវិនិយោគឯកជនចម្រុះរដ្ឋជាមួយធនាគារជាតិនៃកម្ពុជា ហើយក្រោយមក ក៏បានក្លាយទៅជាធនាគារពាណិជ្ជដែលមានដើមទុនផ្ទាល់របស់ខ្លួន១០០% វិញ ។

ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ក៏ត្រូវបានបង្កើតឡើង និងពង្រឹងជាប់ជានិច្ច ដើម្បីជួយសម្រួលដំណើររីកចម្រើននៃវិស័យនេះ ឱ្យប្រព្រឹត្តទៅនៅក្រោមច្បាប់ មានសុវត្ថិភាព និងពង្រឹងបាននូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឆ្នាំ១៩៩៩ ត្រូវបានអនុម័តិសម្រាប់ធ្វើជាមូលដ្ឋានគតិយុត្តមួយយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងពង្រឹងប្រតិបត្តិការគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ឱ្យប្រព្រឹត្តទៅដោយរលូន មានសុវត្ថិភាព និងប្រសិទ្ធភាព ។

បច្ចុប្បន្ន ដោយសារយើងមានក្របខ័ណ្ឌច្បាប់បែបនេះហើយ ទើបវិស័យធនាគារ ត្រូវបានពង្រឹង និងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងផ្នែកវិសាលភាព និងទំហំសកម្មភាព ហើយវិស័យនេះ ត្រូវបានគេចាត់ទុកថា ជាវិស័យដែលមានលក្ខណៈសមាហរណកម្មខ្ពស់ និងបានដើរតួនាទីស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈអន្តរការិយកម្មធនាគារដែលបានគៀងគរធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រការវិនិយោគវិស័យកសិកម្ម និងសេវាកម្ម ប្រកបដោយផលិតភាព ។

ប្រព័ន្ធធនាគារមានការរីកចម្រើន មានសុខភាពល្អ និងបានទទួលការជឿទុកចិត្តពីសាធារណជនជាតិ-អន្តរជាតិរហូតមកដល់បច្ចុប្បន្ននេះ គឺដោយសារតែ :

១- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ បានរួមគ្នាសហការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងវិធានការប្រុងប្រយ័ត្ននានាបានល្អប្រសើរ

២- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរបស់យើង ខិតខំពង្រឹងការគ្រប់គ្រងផ្ទៃក្នុង និងពង្រីកប្រតិបត្តិការរបស់ខ្លួនបានល្អ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់

៣- មានកិច្ចសហការល្អពីអង្គការអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងវិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ (IFC) ជាដើម និង*ពិសេស*គឺ យើងមានស្មារតីសាមគ្គីគ្នាជាលក្ខណៈជាប្រពៃណី និងសមាហរណកម្មក្នុងគ្រួសារធនាគាររបស់យើង ដែលជាកម្លាំងសរុបនាំឱ្យយើងទាំងអស់គ្នាទទួលបានជោគជ័យជាទីមោទនៈ នាពេលបច្ចុប្បន្ននេះ ។

ទន្ទឹមនឹងការពង្រឹងសុខភាពប្រព័ន្ធធនាគារទាំងមូល ធនាគារជាតិនៃកម្ពុជា ក៏ខិតខំអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ក្នុងក្របខ័ណ្ឌច្បាប់របស់ខ្លួន ដើម្បីរក្សាស្ថិរភាពថ្លៃ និងកម្រិតអតិផរណាឱ្យប្រែប្រួលក្នុងរង្វង់មួយអាចគ្រប់គ្រងបានផងដែរ ឆ្ពោះទៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ដោយយល់ឃើញពីភាពចាំបាច់ និងផលប្រយោជន៍របស់សាធារណជនទូទៅ ទើបធនាគារជាតិនៃកម្ពុជា បានរៀបចំចងក្រងឯកសារច្បាប់នេះឡើង ក្នុងគោលបំណងជួយឱ្យធនាគារិក និងវិនិយោគិនថ្មី បានស្វែងយល់ពីកម្រងឯកសារច្បាប់សម្រាប់គ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ *ជាពិសេស* ឱ្យធនាគារិកទាំងអស់ដែលកំពុងធ្វើប្រតិបត្តិការនៅកម្ពុជា ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅថែមទៀត ទាំងផ្នែកទម្រង់ និងខ្លឹមសារ ដើម្បីឱ្យប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ប្រព្រឹត្តទៅដោយរលូន មានសុវត្ថិភាព និងមានប្រសិទ្ធភាពថែមទៀត និងក្លាយជាប្រតិបត្តិករល្អជាមួយធនាគារជាតិនៃកម្ពុជា ។

សៀវភៅកម្រងឯកសារច្បាប់នេះ ពុំមានអ្វីថ្មីនោះទេ គឺ ក្រុមការងារការិយាល័យគតិយុត្តរបស់យើងគ្រាន់តែបានរៀបចំ និងប្រមូលផ្តុំរាល់ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ធ្លាប់អនុវត្តកន្លងមក យកមកចងក្រងឡើងវិញ និងធ្វើចំណាត់ថ្នាក់បែងចែកទៅតាមប្រភេទនៃបទប្បញ្ញត្តិ ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងឡាយយកទៅអនុវត្ត ប្រកបដោយប្រសិទ្ធភាពខ្ពស់ ហើយបទប្បញ្ញត្តិទាំងនេះ នឹងត្រូវធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ ដើម្បីបង្ហាញឱ្យឃើញពីភាពទន់ភ្លន់នៃការអនុវត្ត ឱ្យស្របតាមស្ថានភាពវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី**

ខ្ញុំសង្ឃឹម និងជឿជាក់ថា សៀវភៅកម្រងឯកសារច្បាប់នេះ ពិតជាផ្តល់នូវផលប្រយោជន៍ជាអតិបរមា ចំពោះវិនិយោគិនជាតិ-អន្តរជាតិ និងធនាគារិក ដែលមានបំណងស្វែងយល់ពីក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់អភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ។

ខ្ញុំសូមបញ្ចប់ ដោយដកស្រង់ពីច្បាប់អរិយសត្ថា កាលពី ៥០០ឆ្នាំមុន ដែលចាស់ទុំបុរមបុរាណ លោកបានអប់រំកូនខ្មែររាប់សតវត្សមកហើយ ក្នុងការប្រកបមុខរបរអាជីវកម្ម ថា :

**" វាយលេខទាត់ក្បាច់ សឹងផ្សំសម្រេច ឱ្យបានដឹងដាន**
**ដឹងដើមដឹងចុង ដឹងបង់ដឹងបាន ដឹងគិតប្រមាណ**
**កត់ត្រាបញ្ជី " ។**

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា សូមមានសុខភាពល្អ និងជ័យជំនះគ្រប់ភារកិច្ច ។

**សូមអរគុណ**